អាជ្ញាធរមីន
C.M.A.A

# ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា

## លេខ ២២

# ការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ ក្នុងវិស័យសកម្មភាពមីន

បោះពុម្ពលើកទី១៖ ឆ្នាំ២០២៤

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មី ផ្លូវលេខ ២៧៣ កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរសារ៖ (៨៥៥)២៣ ៨៨១ ៣០៨
អ៊ីមែល៖ info@cmaa.gov.kh
គេហទំព័រ៖ www.cmaa.gov.kh

## ការរក្សាសិទ្ធិ

ឯកសារនេះ គឺជាស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា (CMAS)ដែលត្រូវបានរក្សាសិទ្ធិ។ ហាមយកឯកសារនេះទាំងស្រុង ឬផ្នែកណាមួយនៃឯកសារនេះ ទៅផលិតឡើងវិញ រក្សាទុក ឬចែកចាយក្នុងទម្រង់ណាមួយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមីន។

ឯកសារនេះអាចទទួលបានពីអាជ្ញាធរមីន និងមិនសម្រាប់លក់។

# មាតិកា


ទំព័រ

**អារម្ភកថា** ............ ៣

**សេចក្តីផ្តើម** ............ ៤

**១. វិសាលភាព** ............ ៤

**២. ឯកសារយោង** ............ ៥

**៣. វាក្យសព្ទ និងនិយមន័យ** ............ ៥

**៤. តម្រូវការ ការពិចារណាអំពីយេនឌ័រ និងភាពចម្រុះ** ............ ៧
- ៤.១. គោលការណ៍បញ្ជ្រាបយេនឌ័រ និងភាពចម្រុះ ............ ៧
- ៤.២. លក្ខខណ្ឌតម្រូវ និងការគិតគូរ ............ ៧
  - *៤.២.១. ការរៀបចំផែនការ និងការចាត់អាទិភាព* ............ ៧
  - *៤.២.២. ការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីន/ស.ផ.ស.* ............ ៧
  - *៤.២.៣. ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ* ............ ៨
  - *៤.២.៤. កិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស.* ............ ៩
  - *៤.២.៥. ទំនាក់ទំនងសហគមន៍* ............ ៩
  - *៤.២.៦. គោលការណ៍គាំពារបុគ្គលិក* ............ ១០
  - *៤.២.៧. ការងារ* ............ ១០
  - *៤.២.៨. ការគិតគូរផ្សេងទៀត* ............ ១១

**៥. ការទទួលខុសត្រូវ** ............ ១១
- ៥.១. អាជ្ញាធរមីន ............ ១១
- ៥.២. ភីម៉ាក់ និងម៉ាពូ ............ ១២
- ៥.៣. ប្រតិបត្តិករសកម្មភាពមីន ............ ១២
- ៥.៤. ម្ចាស់ជំនួយ ឬ ភាគីពាក់ព័ន្ធ ............ ១៣

# អារម្ភកថា

ស្តង់ដាអន្តរជាតិសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានស្នើឡើងដោយក្រុមការងារក្នុងសន្និសីទបច្ចេកទេសអន្តរជាតិជាលើកដំបូងនៅប្រទេសដាណឺម៉ាក ក្នុងខែកក្កដា ឆ្នាំ១៩៩៦។ ជាលទ្ធផលលក្ខខណ្ឌនៃការបោសសម្អាតមីន ការបង្កើតស្តង់ដា និងនិយមន័យនៃការបោសសម្អាតមីនជាសាកលត្រូវបានពិភាក្សា និងឯកភាព។ នៅចុងឆ្នាំ១៩៩៦ ស្តង់ដាអន្តរជាតិសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានបង្កើតឡើងដោយក្រុមការងារ ដែលដឹកនាំដោយអង្គការសហប្រជាជាតិ ផ្អែកលើគោលការណ៍ដែលបានឯកភាពនៅប្រទេសដាណឺម៉ាក។ ស្តង់ដាអន្តរជាតិសម្រាប់ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានបោះពុម្ពជាលើកដំបូង ដោយភ្នាក់ងារសេវាកម្មសកម្មភាពមីននៃអង្គការសហប្រជាជាតិ (UNMAS) នៅខែមីនា ឆ្នាំ១៩៩៧។

ចាប់តាំងពីពេលនោះមក វិសាលភាពនៃស្តង់ដាដើមត្រូវបានពង្រីក ដើម្បីដាក់បញ្ចូលផ្នែកផ្សេងៗនៃសកម្មភាពមីន ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវត្តនៃនីតិវិធីប្រតិបត្តិការ ការអនុវត្ត និងបទដ្ឋាននានា។ ស្តង់ដាអន្តរជាតិសម្រាប់ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានកែសម្រួល និងប្តូរឈ្មោះទៅជាស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិ (IMAS) ដែលបានបោះពុម្ពជាលើកដំបូងនៅខែតុលា ឆ្នាំ២០០១។

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) មានតួនាទីក្នុងការបង្កើត កែសម្រួល និងថែរក្សាស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា (CMAS) ដោយផ្អែកលើស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិ និងឧត្តមានុវត្តនានា។ ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា កំណត់នូវលក្ខខណ្ឌតម្រូវអប្បបរមា និងផ្តល់នូវក្របខណ្ឌបច្ចេកទេស សម្រាប់ប្រតិបត្តិករសកម្មភាពមីន រៀបចំបទដ្ឋានប្រតិបត្តិការ (SOP) ដើម្បីធានាបាននូវសុវត្ថិភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងសម្រួលដល់ការអនុវត្តសកម្មភាពមីននានា។ ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ត្រូវបានបង្កើតឡើងជាលើកដំបូងក្នុងឆ្នាំ២០០៥។

អាជ្ញាធរមីនមានភារកិច្ចបង្កើតស្តង់ដា ដោយពិគ្រោះយោបល់ជាមួយប្រតិបត្តិករសកម្មភាពមីន ដើម្បីធានាបាននូវការអនុវត្តដោយរលូន។ នៅពេលសេចក្តីព្រាងស្តង់ដាត្រូវបានរៀបចំ អាជ្ញាធរមីននឹងចែករំលែកសេចក្តីព្រាងជាមួយសមាជិកគណៈកម្មការត្រួតពិនិត្យ និងកែសម្រួលស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា (ដឹកនាំដោយអាជ្ញាធរមីន និងមានការចូលរួមពីប្រតិបត្តិករសកម្មភាពមីន ដែលជាសមាជិក) ដើម្បីធ្វើការពិនិត្យ និងផ្តល់ធាតុចូល។ អាជ្ញាធរមីន មានតួនាទីក្នុងការសម្រេចចុងក្រោយលើស្តង់ដា ដែលមានអនុប្រធានទី១ អាជ្ញាធរមីន ជាអ្នកអនុម័តលើស្តង់ដា។ ដំណើរការបង្កើត និងការកែសម្រួលស្តង់ដាត្រូវអនុវត្តតាមលំនាំខាងលើ។

# យេនឌ័រ និងភាពចម្រុះក្នុងវិស័យសកម្មភាពមីន

## សេចក្តីផ្តើម

ស្តង់ដានេះមានគោលបំណងរំលេចនូវធាតុសំខាន់ៗនៃគោលនយោបាយ និងច្បាប់ជាតិ ព្រមទាំងបទពិសោធន៍ល្អៗក្នុងកម្រិតជាតិ និងអន្តរជាតិ រួមទាំងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា និងស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិ ដើម្បីធានាថាភាគីពាក់ព័ន្ធសកម្មភាពមីនទាំងអស់ចមានសមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះក្នុងកម្មវិធី និងប្រតិបត្តិការសកម្មភាពមីន។

កម្មវិធីសកម្មភាពកម្ចាត់មីននៅកម្ពុជា បាននាំមុខគេលើឆាកអន្តរជាតិជាងពីទេសវត្សរ៍មកហើយ ដោយសម្រេចបាននូវសមិទ្ធផលជាច្រើន ដើម្បីធានាថា សំឡេង និងទស្សនរបស់ស្ត្រី បុរស កុមារី និងកុមារា ព្រមទាំងក្រុមដែលមិនមានភាពតំណាងគ្រប់គ្រាន់ដូចជា ជនមានពិការភាព សហគមន៍ជនជាតិដើមភាគតិច និងបងប្អូនជនជាតិភាគតិច (ដែលប្រើប្រាស់ភាសាកម្រ) ត្រូវបានគិតគូរដោយស្មើភាពគ្នានៅក្នុងសកម្មភាពមីន។

ស្តង់ដានេះដាក់ចេញនូវគោលការណ៍ជាមូលដ្ឋាន សម្រាប់ការតាក់តែងកម្មវិធីកម្ចាត់មីននានានៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងភាពចម្រុះ។ ដូចនេះ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសកម្មភាពមីននៅកម្ពុជា ត្រូវពិចារណា និងអនុវត្តគោលការណ៍មូលដ្ឋាន ព្រមទាំងលក្ខខណ្ឌតម្រូវនៃស្តង់ដានេះ។

លើសពីនេះ ស្តង់ដានេះកំណត់តួនាទី និងភារកិច្ចនៃភាគីពាក់ព័ន្ធនីមួយៗ ដើម្បីធានាថាការពង្រឹងការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះនៅគ្រប់កម្រិតនៃវិស័យសកម្មភាពមីន មានសង្គតិភាព។ ស្តង់ដាត្រូវបានរៀបចំឡើងសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗចំនួន៣ ដូចខាងក្រោម៖

១. ក្រសួង និងស្ថាប័នពាក់ព័ន្ធ
២. ប្រតិបត្តិករសកម្មភាពមីនជាតិ-អន្តរជាតិ និងដៃគូអនុវត្តន៍
៣. ម្ចាស់ជំនួយ និងស្ថាប័នផ្តល់មូលនិធិផ្សេងៗ។

ស្តង់ដានេះរួមបញ្ចូលគ្នានូវគោលនយោបាយ និងការអនុវត្ត ដើម្បីធានាថា ការតាក់តែង និងការអនុវត្តកម្មវិធី រក្សាបាននូវការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងភាពចម្រុះ។

## ១. វិសាលភាព

ស្តង់ដានេះ រៀបរាប់លម្អិតនូវលក្ខខណ្ឌតម្រូវអប្បរមាអំពីយេនឌ័រ និងភាពចម្រុះ សម្រាប់ភាគីពាក់ព័ន្ធក្នុងសកម្មភាពមីននៅកម្ពុជា។ អាជ្ញាធរមីនរំពឹងថា រាល់សកម្មភាពបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ ត្រូវបានគិតគូរ និងផ្តល់ធនធានគ្រប់គ្រាន់ ដើម្បីធានាថា ការបញ្ជ្រាបត្រូវបានអនុវត្តនៅគ្រប់កម្រិតនៃសកម្មភាពមីន ប្រកបដោយប្រសិទ្ធភាព។

## ២. ឯកសារយោង

ឯកសារយោងខាងក្រោម ជាឯកសារសំខាន់ដែលផ្នែកខ្លះនៃឯកសារត្រូវបានដកស្រង់យកមកប្រើប្រាស់សម្រាប់រៀបចំផ្នែកណាមួយ ឬ ខ្លឹមសារទាំងមូលនៃស្តង់ដានេះ៖

- ស្តង់ដា ០៣៖ ការត្រួតពិនិត្យប្រតិបត្តិករបោសសម្អាតមីន
- ស្តង់ដា ១៤៖ ការស្រាវជ្រាវមូលដ្ឋាន
- ស្តង់ដា ១៥៖ ការកាត់បន្ថយផ្ទៃដី
- ស្តង់ដា ១៧៖ ការគ្រប់គ្រងព័ត៌មាន
- ស្តង់ដា ១៩៖ ការគ្រប់គ្រងគុណភាពក្នុងសកម្មភាពមីន
- ស្តង់ដា ២១៖ ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣ នារីរតនៈទី៥
- ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន (២០១៨-២០២៥)
- គោលការណ៍ណែនាំយេនឌ័រ របស់អង្គការសហប្រជាជាតិសម្រាប់កម្មវិធីសកម្មភាពមីន
- គោលការណ៍ណែនាំ ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីននៅកម្ពុជា ឆ្នាំ២០២២

## ៣. វាក្យសព្ទ និងនិយមន័យ

វាក្យសព្ទ និងនិយមន័យដែលប្រើក្នុងស្តង់ដានេះ គឺដកស្រង់ពីគោលការណ៍ណែនាំស្តីពីយេនឌ័រក្នុងកម្មវិធីសកម្មភាពមីន កំណែលើកទី៣ (ឆ្នាំ២០១៩) ដែលរៀបចំដោយភ្នាក់ងារសេវាកម្មសកម្មភាពមីននៃអង្គការសហប្រជាជាតិ (UNMAS) លើកលែងតែវាក្យសព្ទ និងនិយមន័យមួយចំនួន ដែលមានបញ្ជាក់បន្ថែម។ វាក្យសព្ទដែលប្រើក្នុងស្តង់ដានេះត្រូវបានពន្យល់ដូចខាងក្រោម៖

**យេនឌ័រ** សំដៅលើតួនាទី ឥរិយាបថ សកម្មភាព និងចរិតលក្ខណៈ ដែលសង្គមបានផ្តល់ឱ្យនៅពេលណាមួយ ដោយចាត់ទុកថាសមស្របសម្រាប់ស្ត្រី បុរស កុមារី និងកុមារា។ ការប្រែប្រួលយេនឌ័រអាស្រ័យលើបរិបទសង្គម។ ពាក្យថាយេនឌ័រ មិនមែនមានន័យថាជាស្ត្រីទេ គឺនិយាយអំពីទំនាក់ទំនងអំណាចរវាងស្ត្រី និងបុរស ក៏ដូចជាក្នុងចំណោមស្ត្រី និងក្នុងចំណោមបុរស។ យេនឌ័រ គឺជាផ្នែកមួយនៃបរិបទសង្គម-វប្បធម៌ដ៏ទូលំទូលាយ ដែលរួមបញ្ចូលលក្ខណៈផ្សេងទៀត ដូចជា អាយុ ពូជសាសន៍ ក្រុមជនជាតិដើមភាគតិច វណ្ណៈជាដើម។

**ភាពចម្រុះ** សំដៅទៅលើលក្ខណៈអត្តសញ្ញាណដូចជា អាយុ ពូជសាសន៍ ជាតិសាសន៍ ភាសា សាសនា ពិការភាព ទំនោរផ្លូវភេទ អក្ខរកម្ម ស្ថានភាពអនាថា ស្ថានភាពសេដ្ឋកិច្ច-សង្គម និងតំបន់រស់នៅ។ ការយល់ដឹងអំពីភាពចម្រុះ អាចឱ្យយើងប្រើប្រាស់វិធីសាស្ត្ររួមមួយ ដើម្បីឆ្លើយតបទៅនឹងទិដ្ឋភាពចម្រុះដែលពិបាកបែងចែក និងបង្កើតជាការរើសអើងជាប្រព័ន្ធ (នារីរតនៈទី៥)។

**សមភាពយេនឌ័រ** សំដៅដល់គោលការណ៍គ្មានការរើសអើងទៅលើភេទណាមួយ និងគោលដៅដើម្បីឱ្យស្ត្រី បុរស កុមារី កុមារា មានឱកាស តម្លៃ ធនធាន និងផលប្រយោជន៍ដូចៗគ្នា ដោយពិតប្រាកដនៅក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម។

**ការបញ្ជ្រាបយេនឌ័រ** សំដៅដល់យុទ្ធសាស្ត្រ និងវិធានការឆ្លើយតបនឹងវិសមភាពយេនឌ័រក្នុងគោលនយោបាយតាមវិស័យ (សសរស្តម្ភទាំង៥ នៃវិស័យសកម្មភាពមីន) កម្មវិធី លិខិតបទដ្ឋានគតិយុត្តស្ថាប័ន និងគ្រួសារ ។ល។

**ការយល់ដឹងយេនឌ័រ** ជាវិធីសាស្ត្រក្នុងការអនុវត្តសកម្មភាពមីន ដោយពិចារណាពីផលប៉ះពាល់ទៅលើស្ត្រី បុរស កុមារី និងកុមារា ដែលបង្កដោយគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.)។ គោលបំណងសំខាន់នៃការយល់ដឹងយេនឌ័រក្នុងសកម្មភាពមីន គឺដើម្បីអនុវត្តសកម្មភាពមីនដែលគោរព និងផ្អែកលើគោលការណ៍សមភាពយេនឌ័រ (IMAS 04.10)។

**ក្រុមចម្រុះភេទ** គឺជាក្រុមមួយដែលមានបុគ្គលិកទាំងពីរភេទ ហើយមានសមាជិកយ៉ាងហោចណាស់ម្នាក់ជាបុរស ឬម្នាក់ជាស្ត្រី។ នៅក្នុងកាលៈទេសៈខ្លះ យើងអាចបង្កើតក្រុមមួយដែលមានសមាជិកជាស្ត្រីទាំងអស់ និងជាបុរសទាំងអស់ ហើយការធ្វើដូច្នេះគួរផ្អែកទៅលើលទ្ធផលនៃការវិភាគយេនឌ័រ និងភាពចម្រុះ។ ប្រសិនបើអាច ក្រុមចម្រុះយេនឌ័រ ជាជម្រើសល្អ ពិសេសក្រុមដែលធ្វើការជាមួយសហគមន៍។

**គោលការណ៍គាំពារបុគ្គលិក** គឺជាការទទួលខុសត្រូវរបស់ស្ថាប័ន/អង្គភាព ត្រូវធានាថាបុគ្គលិក ប្រតិបត្តិការ និងកម្មវិធីនានា មិនបង្កគ្រោះថ្នាក់ដល់កុមារ និងមនុស្សពេញវ័យដែលងាយរងគ្រោះ ហើយស្ថាប័ន/អង្គភាពនោះ មិនធ្វើឱ្យពួកគេប្រឈមនឹងគ្រោះថ្នាក់ និងការរំលោភបំពាន។ ការការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ រួមទាំងការការពារកុមារ ស្ថិតក្រោមនិយមន័យនៃពាក្យ "ការគាំពារបុគ្គលិក"។

**គោលការណ៍គ្មានការអត់ឱន** មានន័យថា ស្ថាប័ន/អង្គភាពត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់ថាការបៀតបៀនមិនត្រូវបានអត់ឱន និងត្រូវមានចំណាត់ការច្បាស់លាស់។

- ពាក្យ "**ត្រូវតែ**" ត្រូវបានប្រើដើម្បីបញ្ជាក់ពីតម្រូវការចាំបាច់ វិធីសាស្ត្រ ឬ ភាពជាក់លាក់ដែលត្រូវអនុវត្តឱ្យស្របទៅនឹងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជ។
- ពាក្យ "**គួរតែ**" ត្រូវបានប្រើដើម្បីបញ្ជាក់ពីតម្រូវការ វិធីសាស្ត្រ ឬ ភាពជាក់លាក់ផ្សេងៗទៀតដែលបានស្នើឡើង។
- ពាក្យ "**អាច**" ត្រូវបានប្រើដើម្បីបញ្ជាក់ពីវិធី ឬ មធ្យោបាយដែលអាចទទួលយកបាន។

## ៤. គោលការណ៍ និងការពិចារណាអំពីយេនឌ័រ និងភាពចម្រុះ

### ៤.១. គោលការណ៍បញ្ជ្រាបយេនឌ័រ និងភាពចម្រុះ

ភាគីពាក់ព័ន្ធសកម្មភាពមីន គួរតែអនុវត្តគោលការណ៍ខាងក្រោម ឱ្យបានជាអតិបរមាតាមដែលអាចធ្វើបាន៖

- ការរៀបចំផែនការ ការអនុវត្ត និងការរាយការណ៍អំពីប្រតិបត្តិការសកម្មភាពមីន ត្រូវធ្វើឡើងប្រកបដោយបរិយាប័ន្ន ព្រមទាំងគិតគូរអំពីការយល់ដឹងយេនឌ័រ និងភាពចម្រុះ
- អនុវត្តវិធានការគ្មានការអត់ឱនចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវនីតិវិធីការពារការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទចំពោះបុគ្គលិក និងអ្នកទទួលផល
- ជំរុញឱ្យមានតុល្យភាពយេនឌ័រនៅគ្រប់សកម្មភាពមីន និងគ្រប់កម្រិត
- ធានាថាបុគ្គលទាំងអស់ដោយមិនគិតពីភេទ ឬអត្តសញ្ញាណ មានសិទ្ធិទទួលបានអត្ថប្រយោជន៍ពីសកម្មភាពមីនស្មើៗគ្នា។

### ៤.២. លក្ខខណ្ឌតម្រូវ និងការគិតគូរ

លក្ខខណ្ឌតម្រូវអប្បបរមា និងការគិតគូរខាងក្រោម គឺអាចអនុវត្តបានសម្រាប់គ្រប់ភាគីពាក់ព័ន្ធសកម្មភាពមីននៅកម្ពុជា។

#### *៤.២.១. ការរៀបចំផែនការ និងការចាត់អាទិភាព*

នៅពេលរៀបចំផែនការសកម្មភាពមីន អាជ្ញាធរមីន គណៈកម្មាធិការសកម្មភាពមីនខេត្ត (ភីម៉ាក់) អង្គភាពផែនការសកម្មភាពមីនខេត្ត (ម៉ាពូ) ប្រតិបត្តិករសកម្មភាពមីន និងភាគីពាក់ព័ន្ធត្រូវតែ៖

- លើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់អត្តសញ្ញាណយេនឌ័រ រួមទាំងតំណាងពីក្រុមដែលមិនមានភាពតំណាងគ្រប់គ្រាន់ ជនមានពិការភាព សហគមន៍ជនជាតិដើមភាគតិច និងបងប្អូនជនជាតិភាគតិច (ដែលប្រើប្រាស់ភាសាកម្រ) នៅគ្រប់កម្រិតនៃដំណើរការរៀបចំផែនការ
- គិតគូរពីតម្រូវការ និងអាទិភាពរបស់សហគមន៍ដែលមកពីមជ្ឈដ្ឋានផ្សេងៗគ្នា នៅក្នុងដំណើរការចាត់អាទិភាពសម្រាប់ការបោសសម្អាតមីន/ស.ផ.ស.
- ធានាថាគោលនយោបាយគ្មានការអត់ឱន ត្រូវបានប្រកាន់ខ្ជាប់ជាផ្នែកមួយនៃគោលនយោបាយគាំពារបុគ្គលិក
- ផ្តល់អាទិភាពស្មើគ្នារវាងស្ត្រី និងបុរស ក្នុងដំណើរការរៀបចំផែនការ និងការចាត់អាទិភាព។

#### *៤.២.២. ការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីន/ស.ផ.ស.*

ពាក់ព័ន្ធនឹងការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីន/ស.ផ.ស. ប្រតិបត្តិករត្រូវតែ៖

- ផ្តល់កន្លែងស្នាក់នៅដាច់ដោយឡែកសម្រាប់ស្ត្រី និងបុរសនៅតាមការដ្ឋាន

- បែងចែកទិន្នន័យតាមភេទ អាយុ និងពិការភាព ចំពោះអ្នកផ្តល់ព័ត៌មាន អ្នកចូលរួមស្រាវជ្រាវ ជនរងគ្រោះថ្នាក់ និងអ្នកទទួលផល
- ធានាថាក្រុមស្រាវជ្រាវមានចំណេះដឹង ជំនាញ និងធនធានគ្រប់គ្រាន់ (រួមទាំងជំនាញភាសា) ដើម្បីប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ជាមួយសហគមន៍មូលដ្ឋាន
- ធានាថាដំណើរការស្រាវជ្រាវមិនបច្ចេកទេស ស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីន/ស.ផ.ស. គឺប្រព្រឹត្តទៅប្រកបដោយការទទួលខុសត្រូវ ចំពោះសហគមន៍ដែលរងផលប៉ះពាល់។

ពាក់ព័ន្ធនឹងការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីន/ស.ផ.ស. ប្រតិបត្តិករគួរតែ៖

- ធានាថាក្រុមស្រាវជ្រាវមិនបច្ចេកទេស ស្រាវជ្រាវបច្ចេកទេស និងបោសសម្អាតមីន/ស.ផ.ស. មានបុគ្គលិកទាំងពីរភេទ
- ផ្តល់បង្គន់អនាម័យ និងកន្លែងងូតទឹកសមរម្យសម្រាប់ស្ត្រី និងបុរស នៅកន្លែងស្នាក់នៅ និងការដ្ឋាន
- ពិចារណាអំពីវិធីសាស្ត្រផ្សេងៗ ដូចជាការពិភាក្សាជាក្រុមដោយចំហ ការទៅជួបគ្រួសារ និងការប្រជុំដាច់ដោយឡែកជាមួយស្ត្រី និងបុរស ក្នុងករណីចាំបាច់ដើម្បីបង្កើនការចូលរួម
- ធានាថាដំណើរការស្រាវជ្រាវមិនបច្ចេកទេស ស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីន/ស.ផ.ស. គឺប្រព្រឹត្តទៅប្រកបដោយបរិយាប័ន្ន។

### *៤.២.៣. ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ*

ពាក់ព័ន្ធនឹងការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (EORE) ប្រតិបត្តិករត្រូវតែ៖

- ធានាថាក្រុម EORE មានចំណេះដឹង ជំនាញ និងធនធានគ្រប់គ្រាន់ (រួមទាំងជំនាញភាសា) ដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នកទទួលផលប្រកបដោយប្រសិទ្ធភាព
- ធានាថាសម្ភារ EORE ទាំងអស់ប្រើប្រាស់ភាសាដែលងាយយល់ទៅតាមតំបន់
- ធានាថាការអប់រំត្រូវបានធ្វើឡើងទៅតាមពេលវេលា និងទីតាំងដែលសមស្រប ព្រមទាំងងាយស្រួលសម្រាប់ក្រុមគោលដៅ (ស្ត្រី កុមារី កុមារា បុរស និងជនមានពិការភាព) ចូលរួម
- សាកល្បងសម្ភារអប់រំនៅនឹងមូលដ្ឋានជាមួយក្រុមគោលដៅ ដូចជា ស្ត្រី កុមារី កុមារា បុរស និងជនមានពិការភាព ដើម្បីធានាថា សម្ភារអប់រំទាំងនោះងាយយល់
- វិភាគស្ថានភាពយេនឌ័រ និងភាពចម្រុះ ដើម្បីកំណត់ក្រុមគោលដៅ និងភាពងាយរងគ្រោះរបស់ពួកគាត់ មុនពេលធ្វើការអប់រំ
- កែសម្រួលសារអប់រំ ឱ្យឆ្លើយតបទៅនឹងឥរិយាបថប្រថុយប្រថានរបស់ក្រុមគោលដៅ ដែលអាចមានភាពខុសគ្នារវាង ស្ត្រី កុមារី កុមារា និងបុរស
- ធានាថាសម្ភារអប់រំមិនពឹងផ្អែកទាំងស្រុង លើសារសរសេរជាលាយលក្ខណ៍អក្សរ និងជំនួសដោយការប្រើប្រាស់សារអប់រំជារូបភាព ជាពិសេសក្នុងតំបន់ដែលអក្ខរកម្មនៅមានកម្រិត។

ពាក់ព័ន្ធនឹងការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ប្រតិបត្តិករគួរតែ៖

- ប្រមូល និងវិភាគទិន្នន័យដែលបែងចែកតាមភេទ អាយុ និងពិការភាព ដើម្បីស្វែងយល់ពីគំនិត និងទង្វើរបស់ស្ត្រី បុរស កុមារី និងកុមារា និងការយល់ដឹងរបស់ពួកគាត់អំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដើម្បីផ្តល់សារអប់រំឱ្យបានសមស្រប
- ធានាថាក្រុមអប់រំដែលដាក់ពង្រាយ មានបុគ្គលិកទាំងពីរភេទ (យ៉ាងហោចណាស់មានបុរសម្នាក់ ឬ ស្ត្រីម្នាក់)
- ពិចារណាជ្រើសរើសអ្នកផ្តល់សារអប់រំ ដែលជាជនរងគ្រោះថ្នាក់ផ្ទាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- ផ្តល់បទបង្ហាញឱ្យសមស្របទៅនឹងក្រុមគោលដៅ ដើម្បីជំរុញការចូលរួម។

### ៤.២.៤. *កិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស.*

ពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. ភាគីពាក់ព័ន្ធត្រូវតែ៖

- ធានាឱ្យមានអ្នកប្រឹក្សាគាំទ្រចិត្តសង្គមទាំងពីរភេទ ផ្តល់សេវាប្រឹក្សាជូនជនរងគ្រោះផ្ទាល់ទាំងបុរស និងស្ត្រី ឱ្យបានសមស្រប
- ធានាថាការប្រមូលទិន្នន័យអំពី ជនរងគ្រោះ ការរងរបួស តម្រូវការ និងលទ្ធភាពទទួលបានសេវាសង្គ្រោះ មានបែងចែកតាមភេទ អាយុ និងពិការភាព។

ពាក់ព័ន្ធនឹងកិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. ភាគីពាក់ព័ន្ធគួរតែ៖

- បញ្ជូនជនរងគ្រោះទៅទទួលសេវាឱ្យបានសមស្រប ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគាត់
- ធានាឱ្យមានបុគ្គលិកទាំងពីរភេទ ក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្ម
- កំណត់ពេលវេលា ទីតាំង និងវិធីសមស្រប ដើម្បីផ្តល់សេវាជូនស្ត្រី បុរស កុមារី និងកុមារា ដែលជាជនរងគ្រោះផ្ទាល់ ជនមានពិការភាព និងជនរងគ្រោះដោយប្រយោល
- ប្រើប្រាស់កម្រងសំណួរ Washington Group Short Set (WGSS) ជាឧបករណ៍ជំនួយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រមូលទិន្នន័យពិការភាពក្នុងសកម្មភាពមីន
- ធានាឱ្យមានកន្លែងទទួលសេវាដាច់ដោយឡែកសម្រាប់ស្ត្រី និងបុរសនៅពេលចាំបាច់ ដើម្បីរក្សាឯកជនភាព។

### ៤.២.៥. *ទំនាក់ទំនងសហគមន៍*

ភាគីពាក់ព័ន្ធត្រូវតែ៖

- ធានាថាក្រុមទំនាក់ទំនងសហគមន៍មានធនធាន ជំនាញ ចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់ (រួមទាំងជំនាញភាសា) ដើម្បីប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ជាមួយសហគមន៍ដែលរងផលប៉ះពាល់

ភាគីពាក់ព័ន្ធគួរតែ៖

- ធានាថារាល់សកម្មភាពទំនាក់ទំនងសហគមន៍ត្រូវធ្វើឡើង ក្នុងអំឡុងពេល ទីកន្លែង និងប្រើប្រាស់របៀបទំនាក់ទំនងដែលងាយស្រួល និងសមស្របសម្រាប់ក្រុមគោលដៅ (រួមទាំងស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាព)
- ធានាថាក្រុមទំនាក់ទំនងសហគមន៍ មានបុគ្គលិកទាំងពីរភេទ (យ៉ាងហោចណាស់មានសមាជិកជាស្ត្រីម្នាក់ ឬ បុរសម្នាក់)
- ធានាថាកម្មវិធីសកម្មភាពមីនឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពសហគមន៍ ដោយមានការចូលរួមពីសមាជិកសហគមន៍ (រួមមាន ស្ត្រី បុរស កុមារី និងកុមារា រួមទាំងក្រុមដែលងាយរងគ្រោះ) ដើម្បីធានាការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃទៅលើប្រតិបត្តិការសកម្មភាពមីន មានការគិតគូរអំពីយេនឌ័រ និងភាពចម្រុះ។

### *៤.២.៦. គោលការណ៍គាំពារបុគ្គលិក*

ភាគីពាក់ព័ន្ធត្រូវតែ៖

- មានគោលនយោបាយ និងនីតិវិធីជាលាយលក្ខណ៍អក្សរស្តីពី ការការពារពីការកេងប្រវ័ញ្ចការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ
- រៀបចំឱ្យមានយន្តការទទួលបណ្តឹងសារទុក្ខក្នុងស្ថាប័ន និងសម្រាប់សហគមន៍ ដើម្បីឱ្យជនដែលរងគ្រោះពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ អាចរាយការណ៍ និងមាននីតិវិធីដោះស្រាយច្បាស់លាស់
- ផ្តល់ការបណ្តុះបណ្តាល និងវគ្គរំលឹកជាប្រចាំដល់បុគ្គលិក អំពីគោលនយោបាយគាំពារបុគ្គលិក ដើម្បីលើកកម្ពស់ក្រមសីលធម៌ និងគោលការណ៍គ្មានការអត់ឱនចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទនៅក្នុងស្ថាប័ន
- បង្កើតនូវបទបញ្ជាផ្ទៃក្នុង ដែលចែងច្បាស់អំពីអាកប្បកិរិយាសមរម្យ និងមិនសមរម្យ
- រៀបចំកែសម្រួលទំហំការងារឱ្យបានសមរម្យ សម្រាប់បុគ្គលិកស្ត្រីមានផ្ទៃពោះ ដូចជាការផ្តល់កិច្ចការស្រាលជាងមុន និងផ្តល់ពេលវេលាបំពេញការងារសមស្របក្នុងរយៈពេលបំបៅកូន។

ភាគីពាក់ព័ន្ធអាច៖

- រាយការណ៍អំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទទៅអាជ្ញាធរមីន ក្នុងករណីដែលបញ្ហានេះមិនអាចដោះស្រាយបាននៅកម្រិតស្ថាប័ន
- មានគោលនយោបាយពាក់ព័ន្ធ ដែលបង្ហាញពីការប្តេជ្ញាចិត្តចំពោះការមិនរើសអើងយេនឌ័រ និងសមភាព។

### *៤.២.៧. ការងារ*

ភាគីពាក់ព័ន្ធគួរតែ៖

- ជំរុញតុល្យភាពយេនឌ័រនៅគ្រប់ផ្នែក និងគ្រប់កម្រិតក្នុងស្ថាប័ន
- មានគោលនយោបាយជ្រើសរើសបុគ្គលិកប្រកបដោយតម្លាភាព
- ផ្តល់ឱកាសបណ្តុះបណ្តាលស្មើៗគ្នាដល់បុគ្គលិក ដោយមិនគិតពីភេទ អាយុ និងលក្ខណៈចម្រុះផ្សេងៗ ហើយពិចារណាពីតម្រូវការរបស់បុគ្គលិក ចំពោះទីតាំង ពេលវេលា និងផ្តល់ភាពងាយស្រួលក្នុងការចូលរួម
- កំណត់កត្តារាំងជារូបវន្ត និងអរូបវន្តចំពោះស្ត្រីដែលធ្វើការក្នុងផ្នែកប្រតិបត្តិការ និងផ្នែកកស្តុភារក្នុងសកម្មភាពមីន រួមទាំងកត្តាផ្សេងៗដែលរាំងដល់ការងាររបស់ស្ត្រី
- កំណត់គោលដៅ និងយុទ្ធសាស្ត្រ ដើម្បីជំរុញឱ្យមានតុល្យភាពយេនឌ័រ ទាំងបុគ្គលិកក្នុងមុខតំណែងគ្រប់គ្រង និងប្រតិបត្តិការ
- មានគណៈកម្មការសម្ភាសន៍ដែលមានតុល្យភាពយេនឌ័រ ហើយមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងតម្លាភាពសម្រាប់ការវាយតម្លៃបេក្ខជន។

### *៤.២.៨. ការគិតគូរផ្សេងទៀត*

- ប្រសិនបើប្រតិបត្តិការសកម្មភាពមីនត្រូវអនុវត្តនៅក្នុងតំបន់វប្បធម៌ ប្រវត្តិសាស្ត្រ ឬ សាសនា ប្រតិបត្តិករគួរអនុវត្តដោយគោរពទៅតាមប្រពៃណី ជំនឿ ឬ ទំនៀមទម្លាប់/បទដ្ឋាននានានៅទីនោះ
- រាល់វិធានការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះដែលពាក់ព័ន្ធ ដូចមានរៀបរាប់លម្អិតនៅក្នុងស្តង់ដា បទដ្ឋានប្រតិបត្តិការ ឬ ឯកសារផ្សេងទៀត ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព។

# ៥. ការទទួលខុសត្រូវ

## ៥.១. អាជ្ញាធរមីន

- ត្រូវតែសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ដើម្បីគាំទ្រ និងកែលម្អវិធានការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ ព្រមទាំងកំណត់ និងដោះស្រាយរាល់ចំណុចខ្វះខាតក្នុងកម្មវិធីសកម្មភាពមីន
- ត្រូវតែលើកកម្ពស់ឱ្យមានការចូលរួមស្មើភាពគ្នាក្នុងសកម្មភាពមីន និងទទួលបានសេវាជំនួយជនរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី បុរស កុមារី និងកុមារា ដែលជាផ្នែកមួយនៃដំណើរការគ្រប់គ្រងគុណភាព
- ត្រូវតែតាមដានការចូលរួមរបស់ស្ត្រី បុរស កុមារី និងកុមារា ក្នុងសកម្មភាពសកម្មភាពមីន និងការទទួលបានសេវាជំនួយជនរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគាត់ឱ្យបានសមស្រប ដែលជាផ្នែកនៃដំណើរការគ្រប់គ្រងគុណភាព
- ត្រូវតែពិនិត្យឡើងវិញជាប្រចាំ និងកែសម្រួលតាមការចាំបាច់ នូវគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីននៅកម្ពុជា
- ត្រូវតែធ្វើការបែងចែកតាមភេទ អាយុ និងពិការភាព នូវរាល់ទិន្នន័យដែលទាក់ទងនឹងមនុស្ស

- ត្រូវតែតែងតាំងជនបង្គោលយេនឌ័រ ដើម្បីទទួលខុសត្រូវការងារបញ្ជ្រាបយេនឌ័រ និងភាពចម្រុះក្នុងស្ថាប័ន
- គួរតែមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគោលការណ៍ណែនាំស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីននៅកម្ពុជា ឱ្យមានប្រសិទ្ធភាព
- គួរតែធានាថា បុគ្គលិកទទួលបានការបណ្តុះបណ្តាលសមស្រប និងមានការយល់ដឹងច្បាស់លាស់អំពីតួនាទី និងភារកិច្ច ក្នុងការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ
- គួរតែធានាថា ឯកសារគោលនយោបាយពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ គឺអាចរកបានយ៉ាងងាយ និងមានជាភាសាបងប្អូនជនជាតិភាគតិច សម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ព្រមទាំងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- គួរតែធានាថាទិដ្ឋភាពយេនឌ័រ និងភាពចម្រុះត្រូវបានដាក់បញ្ចូលទៅក្នុងបទដ្ឋានប្រតិបត្តិការ និងឯកសារពាក់ព័ន្ធផ្សេងទៀត
- គួរតែពិនិត្យឡើងវិញរាល់ស្តង់ដាកម្ចាត់មីនកម្ពុជា ដោយដាក់បញ្ចូលទិដ្ឋភាពបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ។

## ៥.២. ភីម៉ាក់ និងម៉ាពូ

- ម៉ាពូត្រូវតែបញ្ចូលទិដ្ឋភាពយេនឌ័រ ទៅក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពសកម្មភាពមីន
- គួរតែធានាថា ការរៀបចំ និងកសាងផែនការបោសសម្អាតមីន/ស.ផ.ស.ប្រចាំឆ្នាំ មានការគិតគូរពីការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ ដោយធានាថា មានការចូលរួមពីស្ត្រី បុរស និងជនមានពិការភាពនៅគ្រប់កម្រិត
- គួរតែធានាថា ការត្រួតពិនិត្យការប្រើប្រាស់ដីក្រោយបោសសម្អាតរួច មានការចូលរួមពីស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាព។

## ៥.៣. ប្រតិបត្តិករសកម្មភាពមីន

- គួរតែរៀបចំ រក្សាទុក និងធ្វើបច្ចុប្បន្នភាពបទដ្ឋានប្រតិបត្តិការ និងគោលនយោបាយធនធានមនុស្ស ដោយបញ្ចូលឧត្តមានុវត្តនៃការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ
- គួរតែធានាថា បុគ្គលិកទទួលបានការបណ្តុះបណ្តាលឱ្យយល់ពីសារៈសំខាន់ នៃការរៀបចំកម្មវិធីយេនឌ័រ និងភាពចម្រុះ ព្រមទាំងសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគាត់
- គួរតែរៀបចំគម្រោង និងផែនការសកម្មភាព ដោយគិតគូរពីគោលការណ៍ណែនាំស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីននៅកម្ពុជា និងឧត្តមានុវត្តជាតិ និងអន្តរជាតិ
- គួរតែមានគោលនយោបាយ និងនិតិវិធីផ្ទៃក្នុង ស្តីពីការដាក់បញ្ចូលការធ្វើផែនការ និងការអនុវត្តការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះទៅក្នុងកម្មវិធី ប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលផ្សេងទៀត

- គួរតែលើកកម្ពស់ការយល់ដឹង និងសមត្ថភាពបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ តាមរយៈការបណ្តុះបណ្តាល និងការអភិវឌ្ឍ
- គួរតែធានានូវប្រសិទ្ធភាព និងអនុលោមភាព ដោយដាក់បញ្ចូលឧត្តមានុវត្តនៃការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះទៅក្នុងបទដ្ឋានប្រតិបត្តិការរបស់ខ្លួន
- ត្រូវតែធ្វើការបែងចែកតាមភេទ អាយុ និងពិការភាព នូវរាល់ទិន្នន័យដែលទាក់ទងនឹងមនុស្ស
- គួរតែមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគោលការណ៍ណែនាំស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីននៅកម្ពុជា ឱ្យមានប្រសិទ្ធភាព
- គួរតែធានាថាបុគ្គលិកទទួលបានការបណ្តុះបណ្តាលសមស្រប និងមានការយល់ដឹងច្បាស់លាស់អំពីតួនាទី និងភារកិច្ច ក្នុងការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ
- គួរតែធានាថា ឯកសារគោលនយោបាយពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ គឺងាយរកបាន និងមានជាភាសាបងប្អូនជនជាតិភាគតិច សម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ព្រមទាំងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

## ៥.៤. ម្ចាស់ជំនួយ ឬ ភាគីពាក់ព័ន្ធ

- គួរតែវាយតម្លៃថាតើដៃគូអនុវត្តន៍ បំពេញបានគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងផ្នែកទី៤ នៃស្តង់ដារនេះ រួមជាមួយនឹងយុទ្ធសាស្ត្រ គោលនយោបាយ ឬ ចក្ខុវិស័យយេនឌ័រ និងភាពចម្រុះរបស់ដៃគូអនុវត្តន៍
- គួរតែជំរុញដៃគូអនុវត្តន៍រៀបចំថវិកាឱ្យបានគ្រប់គ្រាន់ ដើម្បីកិច្ចគាំពារបុគ្គលិក ការកសាងសមត្ថភាព ការបណ្តុះបណ្តាល និងសម្ភារចាំបាច់ សម្រាប់ការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះ។

ថ្ងៃ ចន្ទ ៥ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ២០២៤

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១**

CMAA

**បណ្ឌិត លី ធុជ**